ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៤ សរ

# សារាចរ

## ស្ដីពី

## ការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញ

ដោយពិនិត្យឃើញថា កន្លងមក ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈដទៃទៀត បានបង្កើតលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធមួយចំនួន ដែលពុំទទួលបានការពិនិត្យ និងឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង/ឬ លក្ខខណ្ឌនៃលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធទាំងនោះ មានវិសមធម៌ផ្នែកហិរញ្ញវត្ថុសាធារណៈ ចំពោះភាគីរដ្ឋ។ ករណីនេះ អាចធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តនីតិវិធីហិរញ្ញវត្ថុ និងវិន័យហិរញ្ញវត្ថុសាធារណៈ ដែលអាចឈានដល់ការខាតបង់នូវឧត្តមប្រយោជន៍នៃចំណូលមិនមែនសារពើពន្ធ ដែលជាផ្នែកមួយយ៉ាងសំខាន់នៃរចនាសម្ព័ន្ធថវិកាជាតិ។

អនុលោមតាម ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ យុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលនៅជាធរមាន គឺតម្រូវឱ្យមានការត្រួតពិនិត្យ និងការធ្វើនីត្យានុកូលកម្មឡើងវិញ នូវលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ដែលពិនិត្យឃើញមានបញ្ហា ដូចបានរៀបរាប់ខាងលើ។

ក្នុងគោលបំណងពង្រឹងនូវប្រសិទ្ធភាពនៃការគ្រប់គ្រង ការកៀរគរ និងការប្រមូលចំណូលមិនមែនសារពើពន្ធទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យសបតាមការវិវឌ្ឍន៍ជាក់ស្ដែងនៃសង្គម សេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន និងធានាបាននូវប្រសិទ្ធភាព សក្ដិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព នៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន រាជរដ្ឋាភិបាល សូមធ្វើការណែនាំ ដូចខាងក្រោម÷

១. ការធ្វើនីត្យានុកូលកម្ម ត្រូវអនុវត្តតាមរយៈយន្តការ គណៈកម្មការអន្តរក្រសួង ស្ថាប័ន ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានការចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងអង្គភាពនីតិបុគ្គលសារធារណៈដទៃទៀត ដែលពាក់ព័ន្ធ ដើម្បីទទួលបន្ទុកការងារធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការអន្តរក្រសួង ស្ថាប័ន ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២. ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ នីតិបុគ្គលសាធារណៈដទៃទៀត ដែលបានបង្កើតលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ហើយពុំបានទទួលការពិនិត្យ និងឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង/ឬ លក្ខខណ្ឌនៃលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ មានវិសមធម៌ផ្នែកហិរញ្ញវត្ថុសាធារណៈ ដែលនាំឱ្យបាត់បង់ចំណូលថវិការដ្ឋ ត្រូវប្រមូលចងក្រង រៀបចំជាបញ្ជីលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធទាំងនោះ ដើម្បីជាកម្មវត្ថុនៃការធ្វើនីត្យានុកូលកម្មឡើងវិញ មកគណៈកម្មការអន្តរក្រសួង ស្ថាប័ន។

៣. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំប្រកាសដាក់ចេញនូវវិធាន និងនីតិវិធីនៃការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញ ដើម្បីឱ្យកិច្ចការនេះមានប្រសិទ្ធភាព និងស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ នីតិបុគ្គលសាធារណៈដទៃទៀត និងភាគីនៃលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃពុធ ៨កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ